# សេចក្តីណែនាំស្តីពីការបំពេញទិន្នន័យ ក្នុងបញ្ជីកត់ត្រា ផ្នែកវះកាត់តូច

*បោះពុម្ពលើកទី១, ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣*

កំណត់សម្គាល់ ៖
- បញ្ជីកត់ត្រានេះត្រូវប្រើនៅផ្នែកវះកាត់តូច។
- បិទបញ្ជីនៅថ្ងៃចុងក្រោយនៃខែនីមួយៗ។
- សម្រាប់ខែថ្មី កាលបរិច្ឆេទត្រូវសរសេរនៅចំកណ្តាលទំព័រថ្មីនៃសៀវភៅកត់ត្រា។

ត្រូវបំពេញព័ត៌មានលម្អិតនៅបន្ទាត់ (ជួរផ្តេក) តាមការណែនាំខាងក្រោមនូវគ្រប់ករណីទាំងអស់ ៖

| ខ្ទង់ទី | សេចក្តីណែនាំ |
|---|---|
| ១ | *លេខរៀង*<br>ជាលេខរៀង(លេខស្ទីត)តាមលំដាប់។ លេខរៀងនេះត្រូវចាប់ផ្តើមពីលេខ ១និងលេខបន្តបន្ទាប់រហូតដល់ដាច់ខែ។ ចាប់ផ្តើមលេខរៀងថ្មី(លេខស្ទីត)នៅរៀងរាល់ខែថ្មី។ |
| ២ | *លេខកូដអ្នកជំងឺ*<br>ត្រូវចម្លងលេខពីលេខកូដអ្នកជំងឺរបស់មន្ទីរពេទ្យ។ ឧទាហរណ៍៖ 000-000-123-1។ |
| ៣ | *ឈ្មោះអ្នកជំងឺ*<br>សរសេរឈ្មោះពេញ (នាមត្រកូល និងនាមខ្លួន) របស់អ្នកជំងឺ។ |
| ៤ | *ឈ្មោះអាណាព្យាបាល (សម្រាប់កុមារ)*<br>សរសេរឈ្មោះពេញ (នាមត្រកូល និងនាមខ្លួន) របស់អាណាព្យាបាលកុមារ។ |
| ៥ | *អាយុ៖ 0-២៨ ថ្ងៃ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី 0ថ្ងៃ រហូតដល់ ២៨ថ្ងៃ។ ឧទាហរណ៍៖ អាយុ ២0ថ្ងៃ សរសេរលេខ ២0។ |
| ៦ | *អាយុ៖ ២៩ថ្ងៃ-១១ខែ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ២៩ថ្ងៃ រហូតដល់ ១១ខែ។ ឧទាហរណ៍៖ អាយុ ៣0ថ្ងៃ ឬ ១0ខែ ត្រូវសរសេរបញ្ជាក់ថ្ងៃ ឬខែអោយច្បាស់។ |
| ៧ | *អាយុ៖ ១-៤ ឆ្នាំ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ១ឆ្នាំ រហូតដល់ ៤ឆ្នាំ។ ឧទាហរណ៍៖ អាយុ ៣ឆ្នាំ សរសេរ ៣។ |
| ៨ | *អាយុ៖ ៥-១៤ ឆ្នាំ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ៥ឆ្នាំ រហូតដល់ ១៤ឆ្នាំ។ ឧទាហរណ៍៖ អាយុ ៥ឆ្នាំ សរសេរ ៥។ |
| ៩ | *អាយុ៖ ១៥-២៤ ឆ្នាំ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ១៥ឆ្នាំ រហូតដល់ ២៤ឆ្នាំ។ ឧទាហរណ៍៖ អាយុ ២0ឆ្នាំ សរសេរ ២0។ |

| ខ្ទង់ទី | សេចក្តីណែនាំ |
|---|---|
| ១០ | *អាយុ៖ ២៥-៤៩ ឆ្នាំ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ២៥ឆ្នាំ រហូតដល់ ៤៩ឆ្នាំ។ ឧទាហរណ៍៖ អាយុ ៣៥ឆ្នាំ សរសេរ ៣៥។ |
| ១១ | *អាយុ៖ ៥០-៦៤ ឆ្នាំ*<br>សរសេរអាយុជាក់ស្តែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ៥០ឆ្នាំ រហូតដល់ ៦៤ឆ្នាំ។ ឧទាហរណ៍៖ អាយុ ៥៥ឆ្នាំ សរសេរ ៥៥។ |
| ១២ | *អាយុ៖ ≥៦៥ ឆ្នាំ*<br>សរសេរអាយុជាក់ស្តែង បើអ្នកជំងឺមានអាយុចាប់ពី ៦៥ឆ្នាំ ឡើងទៅ។ ឧទាហរណ៍៖ អាយុ ៦៦ឆ្នាំ សរសេរ ៦៦។ |
| ១៣ | *ភេទ៖ ប្រុស*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺភេទប្រុស។ ឧទាហរណ៍៖ ១, ២, ៣... |
| ១៤ | *ភេទ៖ ស្រី*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺភេទស្រី។ ឧទាហរណ៍៖ ១, ២, ៣... |
| ១៥ | *អាស័យដ្ឋានបច្ចុប្បន្ន និងលេខទូរស័ព្ទ*<br>សរសេរអាស័យដ្ឋានបច្ចុប្បន្នរបស់អ្នកជំងឺដែលមកទទួលសេវាមន្ទីរពេទ្យ។ ត្រូវសរសេរភូមិ ឃុំ/សង្កាត់ ស្រុក/ក្រុង/ខណ្ឌ រាជធានី/ខេត្ត និងលេខទូរស័ព្ទ។ |
| ១៦ | *រោគសញ្ញា*<br>សរសេររោគសញ្ញាផ្សេងៗ ដែលអ្នកជំងឺបានរៀបរាប់ប្រាប់។ |
| ១៧ | *អមវេជ្ជសាស្ត្រ*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើគ្រូពេទ្យស្នើសុំសេវាអមវេជ្ជសាស្ត្រ។ ឧទាហរណ៍៖ ១, ២, ៣... |
| ១៨ | *រោគវិនិច្ឆ័យ*<br>សរសេររោគវិនិច្ឆ័យរបស់អ្នកជំងឺដែលកំណត់ដោយគ្រូពេទ្យ។ ឧទាហរណ៍៖ រះបូស។ |
| ១៩ | *ការព្យាបាល*<br>សរសេរតាមវេជ្ជបញ្ជារបស់គ្រូពេទ្យដែលបានផ្តល់អោយអ្នកជំងឺ។<br>ឧទាហរណ៍៖ Para 500mg 1c X 3, Vit.C 500mg 1c X 2, Amoxillin 500mg 1c X 3 |
| ២០ | *បញ្ជូនទៅ (ទៅក្រៅ/សម្រាកពេទ្យ)*<br>សរសេរឈ្មោះទីកន្លែងដែលបានបញ្ជូនអ្នកជំងឺទៅទាំងក្នុងមន្ទីរពេទ្យ និងបញ្ជូនទៅកាន់មន្ទីរពេទ្យ ឬសេវាឯកជនផ្សេងៗ។ |
| ២១ | *ប្រភេទនៃការបង់ថ្លៃសេវា*<br>1. សរសេរ P: សម្រាប់ការបង់លុយដោយខ្លួនឯង។<br>2. សូមសរសេរ HEF: សម្រាប់ការបង់ដោយគំរោងមូលនិធិសមធម៌។<br>3. សូមសរសេរ CBHI: សម្រាប់ការបង់ដោយគំរោងធានារ៉ាប់រងសហគមន៍។<br>4. សូមសរសេរ V(Voucher): ប្រសិនបើគាត់មានប័ណ្ណសុខភាព។<br>5. សូមសរសេរ E: សម្រាប់ករណីលើកលែង។<br>*ចំណាំ៖ រាល់ការបង់ថ្លៃសេវាដោយ HEF ឬ CBHI ឬ V សូមសរសេរលេខកូដដែលស្រង់ចេញពីប័ណ្ណនោះក្នុងខ្ទង់សម្គាល់។* |
| ២២ | *សម្គាល់*<br>ត្រូវសរសេរចំនុចសម្គាល់ផ្សេងៗ ដែលចាំបាច់ទាក់ទងទៅនឹងអ្នកជំងឺ។ |

# សម្រង់តួលេខប្រចាំថ្ងៃ ផ្នែកវះកាត់តូចសម្រាប់មន្ទីរពេទ្យ

| នៃខែ.............ឆ្នាំ............ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| រោគវិនិច្ឆ័យ | អាយុ Group | ករណី | ភេទ | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 | Total |
| (សរសេររោគវិនិច្ឆ័យ) | (សរសេរ ក្រុមអាយុ) | ឈឺ | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឧ. វះបូស | 15-24 ឆ្នាំ | ឈឺ | ប្រុស | 3 | 2 | | 2 | 2 | 1 | 1 | 1 | 1 | | 1 | 1 | 2 | 2 | 1 | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | បញ្ជូនទៅ | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | បញ្ជូន(ទៅក្រៅ/សម្រាកពេទ្យ) | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | P: បង់លុយដោយខ្លួនឯង | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | HEF: គំរោងមូលនិធិសមធម៌ | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | CBHI: គំរោងធានារ៉ាប់រងសុខភាពសហគមន៍ | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | V: ប័ណ្ណសុខភាព | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | E: ករណីលើកលែង | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |